**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៨៤៩ មស. សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែ មេសា ឆ្នាំ២០២០

យោងសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្ស រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយស សូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ឯកឧត្តម លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធមេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារ នៃសារាចរ ដូចមានយោងខាងលើ និងគោលការណ៍ថ្មីៗរបស់រាជរដ្ឋាភិបាល ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងមុខងារ សាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់សហការអនុវត្តដូចខាងក្រោម៖

- សម្រាប់បៀវត្សប្រចាំខែ**មេសា** ឆ្នាំ២០២០ ក្រសួងមុខងារសាធារណៈ សូមស្នើសុំគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ពុំចាំបាច់ធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាលនិងស្ថានភាពគ្រួសារទេ ។
- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សខែ**មេសា** ឆ្នាំ២០២០ ដោយផ្អែកលើទិន្នន័យ ដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែ**មីនា** ឆ្នាំ២០២០ជាគោល និងធ្វើការរៀបចំទិន្នន័យ មួយចំនួនទៀតជាស្វ័យប្រវត្តិទៅតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាល ។
- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធានាការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ**មេសា** ឆ្នាំ២០២០ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួនលើកទី ១ ឱ្យបានមុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងលើកទី ២ ក្នុងសប្តាហ៍ទី ៤ ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ឯកឧត្តម លោក លោកស្រី ប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះតាមការគួរ ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២០
**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរនិងអង្គភាពពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh